ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០១៣

នៅក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើនដោយផ្សារភ្ជាប់បទដ្ឋាន ការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំ លើកទី៣ និងលើកទី៤ នីតិកាលទី៣ នៃព្រឹទ្ធសភា ការរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ ប្រជុំពេញអង្គ ព្រឹទ្ធសភា លើកទី៤ នីតិកាលទី៣ ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់នានា ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងបញ្ហាផ្សេងៗទៀត និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើតសេវាថ្មីៗ ការកសាងគោលនយោបាយនានា ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

-បានចាត់ចែងរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ ប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៤ នីតិកាលទី៣ ចំនួន០៣លើក និងរៀបចំធ្វើបទឧទ្ទេសនាម ស្តីពី "តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា" ប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ អន្តរជាតិ (ជប៉ុន ប្រធានអង្គការ SES) ទទួលសៀវភៅពីស្ថានទូតរុស្ស៊ី ចូលរួមក្នុងជំនួបសវនាការរវាងឯកឧត្តម **សាយ ឈុំ** និងឯកឧត្តម **Vincent EBLE** ប្រធានក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា ចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបានពិនិត្យ សម្រេចលើឯកសារផ្សេងៗចំនួន៤១៧ច្បាប់ ។

## ១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖

-បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៤ ។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: oum_sarith@camnet.com.kh

**២.សេវាទទួលខុសត្រូវការតំណាង៖**

-បានរៀបចំវេទិកាសាធារណៈ ចំនួន០២លើក ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋ នៅខេត្តស្វាយរៀង ខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ ខេត្តព្រះសីហនុ ស្តីពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គោលនយោបាយ វិមជ្ឈការ វិសហមជ្ឈការ និងយេនឌ័រ និងអមដំណើរសមាជិកព្រឹទ្ធសភា ចុះជួបសំណេះសំណាល ចែកអំណោយដល់ប្រជាពលរដ្ឋរងគ្រោះមហន្តរាយដោយទឹកជំនន់ ចំនួន៩០០គ្រួសារ នៅខេត្តកណ្តាល កំពង់ចាម ក្រចេះ ស្ទឹងត្រែង និងខេត្តរតនគិរី ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្ត រាជធានីទូទាំងប្រទេស ចំនួន៦២លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ ព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១០០លើក ។

-ទទួលពាក្យបណ្តឹង ចំនួន០៤ករណី និងបានដាក់ជូនគណៈកម្មការជំនាញ ពិនិត្យសិក្សា ដើម្បីបញ្ជូលទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដោះស្រាយ ។

**៣.សេវាទទួលខុសត្រូវការព័ត៌មាន៖**

-បានអមដំណើរគណៈកម្មការទី១ ទី៦ ទី៨ និងទី៩ ចុះបេសកកម្មទៅខេត្តប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង តាកែវ កំពង់ចាម ក្រចេះ និងពោធិ៍សាត់ ដើម្បីសួរសុខទុក្ខ និងចែកអំណោយប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ ស្វែងយល់អំពីការអនុវត្តច្បាប់ របស់តុលាការ អយ្យការខេត្ត និងមន្ត្រីនគរបាលយុត្តិធម៌ និងរបៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ឃុំ សុខភាពសាធារណៈ ចុះសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មាន និងជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ មន្ទីរពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ។

**៤.ការងារអន្តរជាតិ៖**

រៀបចំបែបបទជូនសមាជិកព្រឹទ្ធសភាចូលរួម ៖

-ទស្សនកិច្ចនៅប្រទេសឡាវ

-ទស្សនកិច្ច នៅសាធារណរដ្ឋបារាំង និងសហព័ន្ធស្វីស

-ទស្សនកិច្ចសិក្សា ស្តីពីការងារបណ្តុះបណ្តាលវិជ្ជាជីវៈ នៅប្រទេសជប៉ុន ។

រៀបចំបែបបទជូនមន្ត្រី អ.ព.ស ចំនួន០២រូប ចូលរួមសិក្ខាសាលា ស្តីពីការគ្រប់គ្រងព័ត៌មាន សម្រាប់អ្នកប្រឹក្សានយោបាយ និងស្រាវជ្រាវ នៅប្រទេសម៉ាឡេស៊ី និង០១រូបទៀត ចូលរួមសន្និសីទ ស្តីពីបម្រែបម្រួលអាកាសធាតុ និងបញ្ហាថាមពលនៅអាស៊ី និងអឺរ៉ុប នៅទីក្រុងហុងកុង ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប្រ៊ុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវ៉េស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៥.ទំនាក់ទំនងសាធារណៈ**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន២២៥នាក់ ។

**៦.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន០៤វគ្គ ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក វគ្គប្រសិទ្ធភាពក្នុងការទំនាក់ទំនងសាធារណៈ វគ្គថែទាំ និងជួសជុលកុំព្យូទ័រ វគ្គ Microsoft office Access 2007 ។

-មន្ត្រីចំនួន ៦៥នាក់ ទទួលអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ នៅតាមសាកលវិទ្យាល័យក្នុងប្រទេស ។

\+ ការបណ្តុះបណ្តាលធនធានមនុស្សក្រៅប្រទេស

-មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់សម្ភារៈឧបទេ្ទសភាសាចិនដល់ជនបរទេស នៅប្រទេសចិន និងមន្ត្រីចំនួន០៤រូប ចូលរួមវគ្គផែនការអភិវឌ្ឍន៍មនុស្ស ០១រូបទៀត ចូលរួមបណ្តុះបណ្តាល ស្តីពីការប្រឆាំង និងឆ្លើយតប និងភេរវកម្មជីវសាស្ត្រនៅប្រទេសម៉ាឡេស៊ី ។

-អាហារូបករណ៍ថ្នាក់បណ្ឌិត និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន២២នាក់ នៅប្រទេសស្វីស ចិន និងវៀតណាម ។

**៧.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-ការអនុវត្តគម្រោងសាងសង់អគារ ៣ជាន់ ៣ខ្នង ជាជំនួយរបស់រដ្ឋាភិបាលចិននឹងត្រូវបញ្ចប់ និងសម្ពោធដាក់ឲ្យប្រើប្រាស់ក្នុងពេលដ៏ខ្លីខាងមុខនេះ។ ភាគីចិនកំពុងសិក្សាគំរោងសាងសង់អគារ ១ខ្នង ៣ជាន់ទៀត សម្រាប់ថ្នាក់ដឹកនាំបំពេញការងារ ។

-រដ្ឋសភាវៀតណាម ឯកភាពផ្ដល់ជំនួយបំពាក់ប្រព័ន្ធ IT នៅក្នុងព្រឹទ្ធសភាកម្ពុជា (អនុវត្តចាប់ពីដើមឆ្នាំ២០១៤)

-ការត្រៀមបំពេញកាតព្វកិច្ចសាងសង់របស់ភាគីព្រឹទ្ធសភា។

**៨. ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង:**

-បានប្រជុំសំរេចអំពីបញ្ហាផ្ទេរមន្ត្រីប្រចាំឆ្នាំ និងបានគិតគូរអំពីការធ្វើសារពើភ័ណ្ឌធនធានមនុស្ស

-រៀបចំប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងច្បាប់ចំនួន០៤ ។

-សហការជាមួយស្ថានទូតជប៉ុន រៀបចំពិធីបំពាក់មេដាយ ជូន**សម្ដេច អគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៅស្ថានទូតជប៉ុន ។

-ចុះបេសកកម្មចំនួន០៦លើក ទៅខេត្តកណ្ដាល ព្រៃវែង ស្វាយរៀង ដើម្បីប្រមូលព័ត៌មានត្រៀមរៀបចំវេទិកា ចូលរួមសិក្ខាសាលា និងរៀបចំវេទិកា

-ចុះបេសកកម្មអមដំណើរគណៈប្រតិភូព្រឹទ្ធសភា ចំនួន០៤លើក ទៅខេត្តកំពង់ចាម តាកែវ បន្ទាយមានជ័យ និងពោធិ៍សាត់ ដើម្បីប្រមូលព័ត៌មានត្រៀមរៀបចំវេទិកា ពិនិត្យស្ថានភាពគ្រោះទឹកជំនន់ ជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ-ខេត្ត-តុលាការ ។

-អង្គភាពបេឡាសោធននិវត្តន៍ សោធនបាត់បង់សម្បទាវិជ្ជាជីវៈ និងគណៈកម្មការត្រួតពិនិត្យ បានរៀបចំបោះឆ្នោតជ្រើសរើសតំណាង មន្ត្រីរាជការ សម្រាប់បន្តអាណត្តិក្រោយ

-ទទួលសៀវភៅពីលោក **Kolesov Sergey** នាយកមជ្ឈមណ្ឌលវិទ្យាស្ថាន និងវប្បធម៌រុស្ស៊ី ចំនួន៨០ក្បាល

-បានបញ្ចប់វាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនការប្រតិបត្តិប្រចាំ ឆ្នាំ២០១៣ បច្ចុប្បន្នភាពផែនការប្រតិបត្តិឆ្នាំ២០១៤ និងការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១៣-២០១៨ ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្ដាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន១២លើក ។

-ថតចម្លងឯកសារ ចំនួន ១៣៩សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន៤៨ក្បាល ដោះស្រាយសំណើថវិកាចំនួន១១៨សំណើ និងសម្ភារ ចំនួន៨៨សំណើ ព្រមទាំងផ្ដល់សេវាដឹកជញ្ជូនចំនួន ១១៩លើក ។

- បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ ទូរស័ព្ទ ទូទឹកកក បន្ទប់ទឹក ត្រចៀកទ្វារ ប្ដូរអំពូល ព្រីកុងតាក់ ចំនួន១០៩គ្រឿង។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន៧៣គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៩៧ប្រធានបទ ។

**II.ទិសដៅការងារខែធ្នូ ឆ្នាំ២០១៣**

១-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៤

២-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ អន្តរជាតិ និងអង្គទូតនានា

៣-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការ និងក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

៤-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស

-សហប្រតិបត្តិការជាមួយវិទ្យាស្ថានធនាគារពិភពលោក ដើម្បីត្រៀមរៀបចំកិច្ចប្រជុំ នាខែធ្នូ ឆ្នាំ២០១៣ នៅភ្នំពេញ ។

-ការត្រៀមរៀបចំជូនគណប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា ទស្សនកិច្ចនៅចិន ។

-ការត្រៀមដំណើរបេសកកម្មរបស់PIC ទៅបារាំង និងស៊ុយអែតក្នុងខែធ្នូ ។

៥-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

៦-ត្រៀមទទួល និងសម្ពោធអគារ៣ខ្នង ៣ជាន់ ជាជំនួយរបស់រដ្ឋាភិបាលចិន ។

៧-ការត្រៀមរៀបចំបំពាក់ការបិនភ្លើង ជណ្តើរយន្ត ប្រព័ន្ធអគ្គិសនី លូទឹក សួនច្បារ នៅក្នុងបរិវេណការដ្ឋាន៣ខ្នង និងក្នុងបរិវេណព្រឹទ្ធសភា ។

៨-រៀបចំលម្អិតថវិកាឆ្នាំ២០១៤ព្រឹទ្ធសភា ឆ្លងគណៈកម្មការទី២ ព្រឹទ្ធសភា និងឆ្លងគណៈកម្មាធិការអចិន្ត្រៃយ៍ ។

-កែលម្អគោលការណ៍ហិរញ្ញវត្ថុសម្រាប់ ឆ្នាំ២០១៤ ។

៩-រៀបចំរបាយការណ៍បូកសរុបទូទាត់ថវិកា ឆ្នាំ២០១៣ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១០-ជម្រុញការបើកវគ្គសិក្សាជំនាញភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ ។

១១-ត្រៀមរៀបចំទិវាសិទ្ធិមនុស្ស១០ធ្នូ ។

១២-បន្តពិចារណាអំពីការរៀបចំ និងដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់៤អង្គភាព ជាជំហាន

ដំបូង ។

១៣-ការគិតគូរដល់ដំណើរការប្រព័ន្ធការងារ មធ្យោបាយ និងធនធានសម្រាប់គ្រប់អង្គភាព ព្រមទាំងជីវភាព សុខុមាលភាព មន្ត្រីរាជការ តាមរបប៣៖ របបសន្តិសុខសង្គម របបធានារ៉ាប់រងសុខភាព និងរបបសោធននិវត្តន៍ ។

-សហការជាមួយរដ្ឋសភា/ក្រុមប្រឹក្សាធម្មនុញ្ញ សិក្សាអំពីបញ្ហាតម្លើងបៀវត្សក្របខ័ណ្ឌ " គ " និង" ឃ " ។

១៤-ត្រៀមរបាយការណ៍ប្រចាំឆ្នាំរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋាន ។

១៥-ត្រៀមពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ។

១៦-បន្តតាមដានគម្រោងសាងសង់អគារថ្មី ជាមួយទីប្រឹក្សាពាណិជ្ជកម្មចិន ។

១៧-បន្តពង្រឹងដំណើរការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។

១៨-ការរៀបចំបំពាក់គ្រឿងឥស្សរិយយសដល់មន្ត្រី និងគិតគូរការរៀបចំសមាសភាពគ្រប់គ្រងអង្គភាពបេឡាសោធននិវត្តន៍ និងគណៈកម្មការត្រួតពិនិត្យបេឡាសោធននិវត្តន៍ ព្រមទាំងគណៈកម្មការនារីរបស់អគ្គលេខាធិការដ្ឋាន ។

១៩-បន្តអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ឥណ្ឌា និងជប៉ុន ( វៀតណាមនឹងជួយរៀបចំប្រព័ន្ធ Intranet ) ។

២០-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភា តាមរយៈវិទ្យាស្ថានសភាកម្ពុជា ។

-កិច្ចសហប្រតិបត្តិការជាមួយ KOICA, JICA, CAMSERV, VN, CHINA, BRUNEI, វិទ្យាស្ថានធនាគារពិភពលោក, វិទ្យាស្ថានសភាកម្ពុជា.

២១-រៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម អគារ៤ខ្នងជាជំនួយរបស់ចិន និងអគារ២ខ្នង ជាជំនួយរបស់ជប៉ុន។

២២-ត្រៀមបូកសរុបប្រចាំឆ្នាំ សារពើភ័ណ្ឌទ្រព្យសម្បត្តិ សារពើភ័ណ្ឌធនធានមនុស្ស/ជំនាញ សារពើភ័ណ្ឌឯកសារ ។

## III.សេចក្តីសន្និដ្ឋាន

-ក្នុងខែវិច្ឆិកានេះ ជាខែដែលមានការឈប់សំរាកច្រើន ហើយក៏ជាខែដែលអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងមមាញឹក លើគ្រប់ការដ្ឋាន ពិសេសការធ្វើរបាយកាណ៍ចន្លោះសម័យប្រជុំ របាយការណ៍តាមវិស័យ រៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ ប្រជុំ

ពេញអង្គ និងបានចុះបេសកកម្ម និងអមដំណើរថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ចុះមូលដ្ឋាន ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធវិស័យជំនាញរបស់គណៈកម្មការ ពិសេសជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់បានទាន់ពេលវេលា ។

បដិសណ្ឋារកិច្ចគណៈប្រតិភូព្រឹទ្ធសភាបារាំង និងការបញ្ជូនគណៈប្រតិភូ ទៅទស្សនកិច្ចនៅប្រទេសបារាំង/ស្វីស/ឡាវ រួមទាំងពិធីប្រគល់គ្រឿងឥស្សរិយយសជាន់ខ្ពស់ជប៉ុន ជូនសម្ដេចប្រធានព្រឹទ្ធសភា ។៚

ភ្នំពេញ,ថ្ងៃទី០៣ខែធ្នូ ឆ្នាំ២០១៣

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**